**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកអគ្គរាជទូតថ្មី នៃព្រះរាជាណាចក្រស៊ុយអែត ចូលជួបសម្តែងការគួរសម

នៅព្រឹកថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានអនុញ្ញាតឲ្យ **ឯកឧត្តម ប្យន ហេកម៉ាក** (Björn Häggmark) ឯកអគ្គរាជទូតថ្មី នៃព្រះរាជាណាចក្រស៊ុយអែត ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួង។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការស្វាគមន៍ និងអបអរសាទរដល់ឯកឧត្តម **ប្យន ហេកម៉ាក** ដែលត្រូវបានតែងតាំងជាឯកអគ្គរាជទូតនៃព្រះរាជាណាចក្រស៊ុយអែត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវសេចក្តីរីករាយដែលប្រទេសទាំងពីរបានថែរក្សាទំនាក់ទំនងល្អតាំងពីឆ្នាំ១៩៦១ ហើយបានថ្លែងអំណរគុណផងដែរដល់រដ្ឋាភិបាល និងប្រជាជនស៊ុយអែត ដែលបានផ្តល់ជំនួយដ៏សំខាន់ដល់កម្ពុជា ក្នុងវិស័យអភិបាលកិច្ច អប់រំ បរិស្ថាន ការងារ សិទ្ធិមនុស្ស ដោះមីន ក៏ដូចជាសាលាក្តីខ្មែរក្រហមជាដើម។ ជំនួយទាំងនេះបានជួយឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដល់កម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា ឯកឧត្តមផ្ទាល់ រួមទាំងថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងពាក់ព័ន្ធ ត្រៀមខ្លួនរួចជាស្រេច ក្នុងការបន្តកិច្ចសហប្រតិបត្តិការជាមួយជាមួយ **ឯកឧត្តមឯកអគ្គរាជទូតថ្មី** ហើយជឿជាក់ថា ទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា-ស៊ុយអែត នឹងត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀត។

ជាការឆ្លើយតប **ឯកឧត្តម ប្យន ហេកម៉ាក** បានសម្តែងនូវសេចក្តីរីករាយដែលបានមកបំពេញការងារជាឯកអគ្គរាជទូតនៅកម្ពុជា។ **ឯកឧត្តម** បានលើកឡើងនូវកិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក និងយុទ្ធសាស្ត្រសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិរបស់ស៊ុយអែតឆ្នាំ ២០២០-២០២៤ សំរាប់រាជរដ្ឋាភិបាលកម្ពុជា ដោយផ្តោតទៅលើវិស័យចំនួន៣៖ ១/ អភិបាលកិច្ច សមភាពយេនឌ័រ និងសិទ្ធិមនុស្ស ២/ ការអប់រំ ទីផ្សារការងារ និង ៣/ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

**ឯកឧត្តមឯកអគ្គរាជទូត** បានធ្វើការកោតសសើរដល់កម្ពុជា ក្នុងការអភិវឌ្ឍផ្នែកបរិស្ថាន វិធានការទប់ទល់ការបម្រែបម្រួលអាកាសធាតុ ហើយកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជូនកងកម្លាំងរក្សាសន្តិភាពទៅកាន់

ប្រទេសផ្សេងៗក្នុងបេសកកម្មរក្សាសន្តិភាព រួមទាំងបេសកកម្មក្នុងការដោះមីននៅក្រៅប្រទេស ដែលជាការរួមចំណែកធ្វើឲ្យពិភពលោកមានសុខសន្តិភាព។

ភាគីទាំងពីរបានពិភាក្សាអំពីការជំរុញអោយទំហំពាណិជ្ជកម្មទ្វេភាគី និងចំនួនភ្ញៀវទេសចរស៊ុយអែតមកកម្ពុជា កាន់តែមានចំនួនកើនឡើង ដោយទំហំពាណិជ្ជកម្មកន្លមកមានចំនួនប្រមាណ៧០ លានដុល្លារ និងភ្ញៀវទេសចរស៊ុយអែតប្រមាណ១៥០០០នាក់ក្នុងមួយឆ្នាំ ប៉ុណ្ណោះ។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើវិស័យសិទ្ធិមនុស្ស កម្ពុជា និងស៊ុយអែត មានយន្តការ **«កិច្ចសន្ទនាផ្នែកសិទ្ធិមនុស្សទ្វេភាគី** (Bilateral Human Right Dialogues)» តាំងពីឆ្នាំ២០០៨ ហើយកន្លងមក ភាគីទាំងពីរបានជួបប្រជុំគ្នាជាប្រចាំដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការអភិវឌ្ឍផ្នែកនេះ។ ឆ្លៀតឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្នើដល់រដ្ឋាភិបាលស៊ុយអែត ឲ្យពិចារណាបន្តផ្តល់ជំនួយផ្នែកដោះមីនឡើងវិញ បន្ទាប់ពីបានផ្អាកនាពេលកន្លងមក។

ក្រៅពីនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមឯកអគ្គរាជទូត** បានផ្លាស់ប្តូរទស្សនៈគ្នាផងដែរអំពីបញ្ហាតំបន់ និងអន្តរជាតិ ហើយនិងបានសន្យាធ្វើការរួមគ្នា ដើម្បីធ្វើឲ្យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែមានភាពជិតស្និទ និងរឹងមាំថែមទៀត។